# យុទ្ធសាស្ត្រទី ៣ : ការជម្រុញអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម

ការជម្រុញអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម ក្រសួងមានសកម្មភាពគឺ :

- ការបង្កើតប្រព័ន្ធសន្តិសុខសង្គម
- ការកែលំអគោលការណ៍ជាធរមាន ដែលទាក់ទងនឹងការធានារ៉ាប់រងគ្រោះថ្នាក់ការងារ ។

## ១. ការបង្កើតប្រព័ន្ធសន្តិសុខសង្គម

ការបង្កើតប្រព័ន្ធសន្តិសុខសង្គម ក្រសួងមានគោលបំណងជាសំខាន់ គឺការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ដែលជាយន្តការមួយដ៏សំខាន់មានភារកិច្ចគ្រប់គ្រងចាត់ចែង របបសន្តិសុខសង្គម ដើម្បីជាប្រយោជន៍សម្រាប់កម្មករនិយោជិត ស្របទៅតាមការកំណត់របស់ច្បាប់និងបទបញ្ញានានា ។

សកម្មភាព ក្នុងការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមរួមមាន:

- រៀបចំ និងតាក់តែងសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតបេឡាសន្តិសុខសង្គម (ប.ស.ស)
- រៀបចំលិខិតតូបករណ៍គតិយុត្តដទៃ
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសន្តិសុខសង្គម
- លើកកំពស់សមត្ថភាពមន្ត្រីសន្តិសុខសង្គម

- ផ្សព្វផ្សាយ និងអនុវត្ត
- រៀបចំដំណើរការរបបសន្តិសុខសង្គម ។

## ២. ការកែលំអគោលការណ៍ជាធរមានដែលទាក់ទងនឹងការធានារ៉ាប់រងគ្រោះថ្នាក់ការងារ

ក្នុងការកែលំអគោលការណ៍ជាធរមាន ដែលទាក់ទងនឹងការធានារ៉ាប់រងគ្រោះថ្នាក់ការងារ គោលបំណងជាសំខាន់របស់ក្រសួង គឺការរៀបចំតារាងកាលិកគ្រោះថ្នាក់ការងារបច្ចុប្បន្ន ឱ្យបានស្របទៅតាមរបបសន្តិសុខសង្គម ស្ថិតក្នុងប្រព័ន្ធដែល ក្រសួងនឹងត្រៀមបង្កើតនាពេលអនាគត ។

ដើម្បីសម្រេចបាននូវ ការរៀបចំតារាងកាលិកគ្រោះថ្នាក់ការងារបច្ចុប្បន្នឱ្យបានសមស្របតាមរបបសន្តិសុខសង្គម ដែលត្រៀមបង្កើតនាពេលអនាគត សកម្មភាពដែលត្រូវអនុវត្តរួមមាន :

- រៀបចំ និងធ្វើសេចក្តីព្រាងកែលំអប្រកាសលេខ ២៤៣
- រៀបចំ និងដាក់ចូលទៅក្នុងការប្រជុំគណៈកម្មការប្រឹក្សាការងារ
- ផ្សព្វផ្សាយ និងចាប់ដំណើរការអនុវត្តប្រកាសស្តីពីបញ្ហានេះ

អគ្គនាយកដ្ឋានការងារនឹងសិក្សាស្រាវជ្រាវ អំពីវិស័យការងារដោយមាន ទិសដៅបង្កើតអោយមានវិទ្យាស្ថានជាតិស្រាវជ្រាវវិស័យការងារ ក្នុងគោលបំណងសិក្សាស្រាវជ្រាវរាល់បញ្ហាក្នុងវិស័យការងារ កសាងសមត្ថភាព ក្របខ័ណ្ឌមន្ត្រី ការងារពិសេសបណ្តុះបណ្តាលឱ្យទៅជាក្របខ័ណ្ឌមន្ត្រីអធិការការងារ អភិបាលការងារ អធិការពេទ្យការងារ និងរៀបចំឱ្យមានគោលនយោបាយជាតិស្តីពីប្រាក់ឈ្នួល ។